**UNITED NATIONS**
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

**NATIONS UNIES**
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia

**តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា**

COHCHR

## លោកឧត្តមស្នងការស្តីទីទទួលបន្ទុកសិទ្ធិមនុស្សអំពាវនាវអោយមានការស៊ើបអង្កេត លើករណីឃាតកម្ម ប្រធានសហជីពសេរីកម្មករកម្ពុជា

លោក ប៊ែរ ត្រិន រ៉ាមចារ៉ាន់ ឧត្តមស្នងការអ.ស.បស្តីទីទទួលបន្ទុកសិទ្ធិមនុស្សបានធ្វើការថ្កោលទោស ចំពោះករណីឃាតកម្មលើរូបលោក ជា វិជ្ជា ប្រធានសហជីពសេរីកម្មករកម្ពុជា និងអំពាវនាវដល់អាជ្ញាធរនានារបស់កម្ពុជា សុំអោយខិតខំយកអស់សមត្ថភាព ដើម្បីនឹងនាំខ្លួនឃាតករ និងមេខ្លោងទៅអោយតុលាការដើម្បីកាត់ទោស ។

ថ្នាក់ដឹកនាំនយោបាយជាន់ខ្ពស់បំផុតក្នុងប្រទេស ត្រូវចេញសេចក្តីថ្លែងការច្បាស់លាស់មួយ ដោយបញ្ជាក់ថាជនទាំងឡាយដែលត្រូវទទួលខុសត្រូវនៅក្នុងករណីឃាតកម្មនេះ ត្រូវតែផ្តន្ទាទោសទៅតាមច្បាប់ ។ លោក រ៉ាមចារ៉ាន់ បានថ្លែងថា បញ្ហានិទណ្ឌភាពឋិតនៅជាឧបសគ្គមួយដ៏ធំដល់ដំណើរការក្នុងការកសាងស្ថាប័នប្រជាធិប-តេយ្យ និងការលើកស្ទួយសិទ្ធិមនុស្ស ស្របតាមនីតិរដ្ឋនៅក្នុងប្រទេសកម្ពុជា ។

លោក ជា វិជ្ជា ដែលជាប្រធានដឹកនាំអង្គការសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានគេបាញ់សំលាប់ កាលពី ថ្ងៃទី ២២ មករា ឆ្នាំ ២០០៤ គឺជាករណីឃាតកម្មចុងក្រោយក្នុងចំណោមករណីធ្វើឃាត និងប៉ុនប៉ងធ្វើឃាតលើរូបឥស្សរជនសំខាន់ៗ នៅក្នុងប្រទេសកម្ពុជាជាច្រើនករណី ដែលបានកើតមានជាបន្តបន្ទាប់នៅក្នុងឆ្នាំកន្លងទៅនេះ ។ តាមសេចក្តីរាយការណ៍ លោក ជា វិជ្ជា ធ្លាប់បានទទួលការគំរាមកំហែងដល់ជីវិត ជាច្រើនលើក នៅក្នុងអំឡុងពេលប៉ុន្មានខែកន្លងទៅនេះ មុនពេលដែលរូបលោកត្រូវបានគេធ្វើឃាត ។

ដោយចង្អុលបង្ហាញផងដែរអំពីសេចក្តីរាយការណ៍ ស្តីពីករណីឃាតកម្មមួយចំនួនលើសកម្មជននៃគណបក្សប្រឆាំង នៅថ្នាក់មូលដ្ឋានក្នុងរយៈពេលប្រាំមួយខែកន្លងទៅនេះ លោក រ៉ាមចារ៉ាន់ បានគូសបញ្ជាក់ថា រដ្ឋទាំងអស់ត្រូវមានកាតព្វកិច្ចក្នុងការការពារប្រជាពលរដ្ឋរបស់ខ្លួន អោយរួចចាកផុតពីការសំលាប់ជីវិតតាមទំនើងចិត្ត ហើយត្រូវតែផ្តល់ការការពារយ៉ាងសកម្ម ពេលណាដែលមានបុគ្គលណាម្នាក់បានប្រឈមមុខនឹងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ។

ត្រូវរៀបចំ និងចាត់វិធានការអោយមានការស៊ើបអង្កេតមួយយ៉ាងល្អិតល្អន់ និងមិនលំអៀង ដើម្បីរែកមុខរកអោយឃើញ ទាំងជនដៃដល់ដែលត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះការធ្វើសំលាប់លោក ជា វិជ្ជា ផង និងទាំងអ្នកដែលបញ្ជាអោយធ្វើឃាតនេះផង ។ លោកឧត្តមស្នងការអ.ស.បស្តីទីបានបន្តមានប្រសាសន៍ដោយសង្ឃឹមថា តុលាការនឹងបើកសវនាការកាត់ទោស នៅពេលណាមួយខាងមុខ ប្រកបដោយតម្លាភាពទាំងស្រុង និងស្របទៅតាមនីតិវិធីត្រឹមត្រូវតាមច្បាប់ ដូចដែលមានចែងធានានៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា និងនៅក្នុងអនុសញ្ញាអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស ដែលប្រទេសកម្ពុជាបានចូលជាភាគី ។

២៦ មករា ឆ្នាំ ២០០៤

#16A, Mao Tse Tuong Blvd, Sangkat Tonle Bassac, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587 E-mail: cohchr@online.com.kh
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លេខ ១៦A មហាវិថី ម៉ៅ សេទុង សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: ៨៥៥-២៣ ៩៨៧ ៦៧១ / ៩៨៧ ៦៧២ / ៩៩៣ ៥៩០ / ៩៩៣ ៥៩១ / ឬ ២១៦ ៣៤២ ទូរសារ: ៨៥៥-២៣ ២១២ ៥៧៩ ឬ ២១៣ ៥៨៧